**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

-------------------

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨០ /០៩-០២-២០១០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

**សាលដីកា**

លេខ: ២១ "ឈ" / ២១-១២-២០១០

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១៤-១២-២០១០ ដោយមានសមាសភាពដូចតទៅ :

**ក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ : ៨០ /០៩-០២-២០១០ រវាង :

**ជនជាប់ចោទ :**

១-ឈ្មោះ [redacted] ផល ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើស្រែ ទីលំនៅ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] គ្មានកូន ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ១៤-៥-២០០៩ "នៅពន្ធនាគារខេត្តបាត់ដំបង" ។

-មានមេធាវីការពារជនជាប់ចោទលោក [redacted] សុផង់ ។

២-ឈ្មោះ [redacted] **ភីភ៉ា ហៅ ចាំរ** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើស្រែ ទីលំនៅភូមិ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] រ នៅលីវ ទោសពីមុនគ្មាន "ក្រៅឃុំ" ។

<u>ត្រូវចោទពីបទ:</u> ប៉ុនប៉ងធ្វើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិថ្មី ឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០-៥-២០០៩ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅក្រុមទី ០៦ ភូមិថ្មី ឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង ។

## ងរឿងហេតុមានដូចតទៅ :

កាលពីថ្ងៃទី ១០-៥-២០០៩ ម៉ោងប្រហែល ១១ជាងយប់ កូនប្រុសខ្ញុំបាទឈ្មោះ [redacted] សល់ បានអង្គុយលេង ពេលនោះ ឈ្មោះ [redacted] ភីភ៉ា និង ឈ្មោះ [redacted] ផល បានយកគ្រាប់បែកថ្លៃគប់មកលើកូនប្រុសខ្ញុំបាទកំពុងអង្គុយប្រាជ្ញលេងជាមួយគ្នាវា ពេលនោះគ្រាប់បែកបានផ្ទុះបណ្តាលឱ្យកូនខ្ញុំបាទរងគ្រោះថ្នាក់ត្រូវដៃ និង ជើងរបួសយ៉ាងធ្ងន់ធ្ងរ ដោយជនល្មើសនោះបំណងគប់គ្រាប់បែកផ្ទុះស្លាប់តែម្តង ។ ខ្ញុំបាទតាំងខ្លួនជាដើមបណ្តឹងជំនួសកូនខ្ញុំបាទដោយទាមទារសំណងចំនួន ៦.០០០.០០០រៀល "ប្រាំមួយលានរៀល" និង សុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

បានឃើញសាលក្រមលេខ ១៣១ "ង" ចុះថ្ងៃទី ១៦-១២-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសំរេចសេចក្តីដូចខាងក្រោម :

១-ប្តូរឈ្មោះបទល្មើសលើឈ្មោះ [redacted] ផល និង ឈ្មោះ [redacted] ភីភ៉ា ហៅ បាវ ពីបទ : ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា មកជាបទ ប៉ុនប៉ងធ្វើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិថ្មី ឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០-៥-២០០៩ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោស

ក-ឈ្មោះ [redacted] ផល ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៥ឆ្នាំ "ដប់ប្រាំឆ្នាំ" គិតពីថ្ងៃឃាត់ខ្លួន ពីថ្ងៃទី ១១-៥-២០០៩ ។

ខ-ឈ្មោះ [redacted] ភីភ៉ា ហៅ បាវ ភេទប្រុស អាយុ ២៧ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៥ឆ្នាំ "ដប់ប្រាំឆ្នាំ" គិតពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តក្នុងពន្ធនាគារ ។

ពីបទ : ប៉ុនប៉ងធ្វើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិថ្មី ឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១០-៥-២០០៩ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

៣-បន្តការឃុំខ្លួនលើឈ្មោះ [redacted] ផល រហូតអនុវត្តទោសខាងលើចប់ជាស្ថាពរ ។

៤-បង្គាប់ឱ្យសមត្ថកិច្ចចាប់ខ្លួនឈ្មោះ [redacted] ភីភ៉ា ហៅ បាវ មកអនុវត្តក្នុងពន្ធនាគារតទៅ ។

៥-បង្គាប់ឱ្យឈ្មោះ [redacted] ផល និង ឈ្មោះ [redacted] ភីភ៉ា ហៅ បាវ រួមគ្នាសងសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ៦.០០០.០០០ រៀល "ប្រាំមួយលានរៀល" ឱ្យទៅឈ្មោះ [redacted] សឿត ជាដើមបណ្តឹងរដ្ឋប្បវេណី ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផល និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សឿត កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ភីភ៉ា ហៅ បាវ ខាងលើ ។ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



Scanned with CamScanner

## នាពេលសវនាការ

## ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ផល "អវត្តមាន"

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សឿត "អវត្តមាន"

-ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សី ។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ផល គួរតំកល់សាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

## មេធាវីធ្វើសេចក្តីសន្និដ្ឋាន

សំណូមពរសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំផង ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យ ឯកសារក្នុងសំណុំរឿងហើយ ។

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ ។

## <u>សំអាងហេតុ</u>

**<u>យល់ឃើញថា</u> :**

១-បណ្តឹងឧទ្ធរណ៍លេខ 0៤ ចុះថ្ងៃទី 0៥-0១-២0១0 របស់ជនជាប់ចោទឈ្មោះ [redacted] ផល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២-តាមចំលើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] ផល មិនទទួលស្គាល់នូវអំពើល្មើសច្បាប់របស់ខ្លួនឡើយ ។ ដោយឆ្លើយបដិសេធថា នៅយប់កើតហេតុនោះ ខ្លួនកំពុងមើលវីដេអូនៅផ្ទះគេ ពុំបានចេញទៅណាទេ ហើយបានលឺសំលេងផ្ទុះដែរ តែពុំបានទៅមើលទេ ឯឈ្មោះ [redacted] ភីយ៉ា ទើបស្គាល់ ហើយវាទៅមើលវីដេអូមួយភ្លែត ការឆ្លើយនេះវាផ្ទុយទៅនឹងចំលើយ សាក្សីដោះបន្ទុកថា ឃើញតែឈ្មោះ [redacted] ផល តែម្នាក់មើលវីដេអូរហូតដល់ចប់ ថាបានលឺសំលេងផ្ទុះ ថាវីដេអូចាក់សំលេងលួម ឯសាក្សីឈ្មោះ [redacted] ខា ជាផ្ទុះថា មិនលឺសំលេងផ្ទុះទេ ព្រោះគាត់បើកសំលេងវីដេអូខ្លាំង ។ ចំលើយទាំងនេះ ក៏វាផ្ទុយស្រឡះនឹង ចំលើយរបស់ជនរងគ្រោះឈ្មោះ [redacted] សល់ និង ឈ្មោះ [redacted] ចន្ទ នៅនឹងកន្លែងកើតហេតុ និង ចំលើយសាក្សីឈ្មោះ [redacted] ចាន់នី និង ឈ្មោះ [redacted] ចាន់នី ដែលបានឃើញជនជាប់ចោទទាំងពីរដើរជាមួយគ្នា សំដៅទៅកន្លែងកើតហេតុ ។ មួយសន្ទុះក្រោយមកក៏លឺ-



Scanned with CamScanner

ស្ទូរសំលេងផ្ទះ នេះបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពិតជាមានបំណងបោកគ្រាប់បែកគប់ទៅលើជនរងគ្រោះ ស្លាប់តែជនរងគ្រោះមិនស្លាប់ អង្គហេតុគឺបណ្តាលមកពីជនជាប់ចោទធ្លាប់មានទំនាក់ទំនងជាមួយជនរងគ្រោះ មក។

៣-មានពិរុទ្ធភាពនិងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទពីបទ ប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន។

៤-សាលក្រមព្រហ្មទណ្ឌលេខ ១៣១ ង ចុះថ្ងៃទី ១៦-១២-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង បាន សំរេចសេចក្តីត្រឹមត្រូវតាមអង្គហេតុនិងអង្គច្បាប់ហើយ គ្រាន់តែមានការភ័ន្តច្រលំថា ភស្តុតាងដែលសមត្ថកិច្ចចាប់ យកបាន មានក្រដាស់ប្រឡាក់រំសេវចំនួន ៤ ចំណែកបញ្ជូនមកព្រះរាជអាជ្ញា តែលោកព្រះរាជអាជ្ញាមិនបញ្ជូនមក តុលាការហើយតុលាការមិនអាចសំរេចអំពីបញ្ហានេះបានទេ គឺមិនត្រឹមត្រូវទេ សាលាឧទ្ធរណ៍បានពិនិត្យក្នុងសំណុំ រឿងនេះហើយ ឃើញមានកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី ១៤-០៥-២០០៩ របស់អយ្យការ និងមានកញ្ចប់កិប ជាប់នឹងសំណុំរឿងដាក់ជាកញ្ចប់វត្ថុតាង ដូចនេះសាលាឧទ្ធរណ៍នឹងសំរេចរឹបអូសវត្ថុតាងនេះ ដើម្បីបំផ្លាញចោទ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី ០៥-០១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ផល ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣១ ង ចុះថ្ងៃទី ១៦-១២-២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

៣-រឹបអូសវត្ថុតាងដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងនៅអយ្យការ ចុះថ្ងៃទី ១៤-០៥-២០០៩ ដើម្បី បំផ្លាញចោល។

៤-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ផល តាមច្បាប់។

សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី-១៤-១២-២០១០ ប្រកាសជាសាធារណៈនៅថ្ងៃទី ២១-១២- ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវតវ៉ាក្នុង កំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាល ដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី |ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ០... ខែ ៤... ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner